លេខ ៥២ ចេញផ្សាយថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែតុលា ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មថ្នាក់ជាតិ.......... ទំព័រទី១
- សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្ទៃក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.).......... ទំព័រទី២
- កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន-ស្ថាប័ន ដើម្បីពិភាក្សាលើការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល.......... ទំព័រទី២
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៦.......... ទំព័រទី២
- ពិធីប្រគល់ប័ណ្ណសរសើរ និងមេដាយ ដល់និស្សិតឆ្នើម ឆ្នាំសិក្សា២០២៤-២០២៥. ទំព័រទី៣
- វិធីប្រកាសដាក់ឱ្យដំណើរការ "ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា".......... ទំព័រទី៣
- ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមអភិវឌ្ឍន៍វិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា".......... ទំព័រទី៣
- សន្និសីទមូលបត្រប្រចាំឆ្នាំ២០២៥.......... ទំព័រទី៤
- កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែតុលា ឆ្នាំ២០២៥.......... ទំព័រទី៤
- វគ្គបណ្តុះបណ្តាលស្តីពី "មូលដ្ឋានគ្រឹះនៃការរៀបចំសូចនាករវាស់វែងសមិទ្ធកម្ម"..... ទំព័រទី៤
- កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.......... ទំព័រទី៥
- កិច្ចប្រជុំស្តីពី "សេចក្តីព្រាងផែនការសកម្មភាព និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា".......... ទំព័រទី៥
- សកម្មភាពចុះត្រួតពិនិត្យវឌ្ឍនភាពកិច្ចគាំពារបរិស្ថាន និងសង្គម របស់សមាជិកសហគមកសិកម្មដែលទទួលបានឥណទានពី គម្រោងACSEP-PIU1...... ទំព័រទី៦
- កិច្ចប្រជុំពិភាក្សារវាង ន.ប.ធ. និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ".......... ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ.......... ទំព័រទី៦
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០.......... ទំព័រទី៧
- កម្មវិធី Industrial Transformation ASIA-PACIFIC (ITAP) 2025.......... ទំព័រទី៧
- កម្មវិធី "វេទិកាការផ្តួចផ្តងគ្រឹះស្ថានហិរញ្ញវត្ថុ ជាមួយកសិធុរកិច្ច សហគមន៍កសិកម្ម និងការដាក់តាំងបង្ហាញផលិតផលកសិកម្ម ក្រោមឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម".......... ទំព័រទី៧
- កិច្ចប្រជុំលើកទី៣ ប្រចាំឆ្នាំ២០២៥ ស្តីពី "ធនធានមនុស្ស និងបច្ចេកវិទ្យាការងារ (The 3rd HR & WorkTech Summit Indonesia 2025".......... ទំព័រទី៨
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ.......... ទំព័រទី៩
- វគ្គបណ្តុះបណ្តាលស្តីពី "ហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម និងការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)".......... ទំព័រទី៩
- កម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥".......... ទំព័រទី១០
- កម្រងសកម្មភាពក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ក្រោមប្រធានបទ "បរធនបាលកិច្ចជាថ្នាលធុរកិច្ចប្រកបដោយទំនុកចិត្ត និងអនុលោមភាពច្បាប់"..... ទំព័រទី១០


## កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មថ្នាក់ជាតិ

នាព្រឹកថ្ងៃពុធ ៩កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ **លោក យុន វាសនា** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មថ្នាក់ជាតិ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ហាច រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ ស្ថាប័ន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមប្រព័ន្ធ ZOOM.




រូបភាព៖ កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មថ្នាក់ជាតិ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh    www.facebook.com/trustregulatorcambodia    (855) 23 237 888

## សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្នែកក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែតុលា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានចូលរួមសិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្នែកក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមការដឹកនាំរបស់ **ឯកឧត្តម គុយ សាខុធ** ទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ** នៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្នែកក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន-ស្ថាប័ន ដើម្បីពិភាក្សាលើការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែតុលា គ.ស. ២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម នេន ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.**, **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច**នៃ **ន.ប.ធ.** និងសហការី បានចូលរួមកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន-ស្ថាប័ន ដើម្បីពិភាក្សាលើការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, អនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម និងជាប្រធានក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធ និងចំណុះ **គសហវ** នៅទីស្តីការ **គសហវ**។



រូបភាព៖ កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន-ស្ថាប័ន ដើម្បីពិភាក្សាលើការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៦

នាព្រឹកថ្ងៃសុក្រ ១១កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែតុលា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងឯកឧត្តមអគ្គនាយក ដែលជាសមាជិក-សមាជិកានៃ **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៦។

## ពិធីប្រគល់ប័ណ្ណសរសើរ និងមេដាយ ដល់និស្សិតឆ្នើម ឆ្នាំសិក្សា ២០២៤-២០២៥

នាព្រឹកថ្ងៃសុក្រ ១១កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣ ខែតុលា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេឡធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកម្មវិធី "ពិធីប្រគល់ប័ណ្ណសរសើរ និងមេដាយដល់និស្សិតឆ្នើម ឆ្នាំសិក្សា ២០២៤-២០២៥" ក្រោមអធិបតីភាពរបស់ **លោក ប៊ុន សុន្ទរង្គ នាយកវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ** ព្រមទាំងមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន នៅអគារ ហត្ថាថោវើ ។



រូបភាព៖ ពិធីប្រគល់ប័ណ្ណសរសើរ និងមេដាយ ដល់និស្សិតឆ្នើម ឆ្នាំសិក្សា ២០២៤-២០២៥។

## វិធីប្រកាសដាក់ឱ្យដំណើរការ "ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ១៤កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែតុលា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេឡធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមវិធីប្រកាសដាក់ឱ្យដំណើរការ "ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម** ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅសណ្ឋាគាររ៉េស៊ីដង់សុខា ភ្នំពេញ។



រូបភាព៖ វិធីប្រកាសដាក់ឱ្យដំណើរការ "ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា"។

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមអភិវឌ្ឍន៍វិស័យមូលបត្រ នៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ១៤កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែតុលា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេឡធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមអភិវឌ្ឍន៍វិស័យមូលបត្រ នៅព្រះរាជាណាចក្រកម្ពុជា" រវាង និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងសមាគមសិល្បករខ្មែរ (**ស.ស.ខ.**) និងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី "កិច្ចសហប្រតិបត្តិការភាពជាដៃគូអាជីវកម្មរវាងក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក និង ក្រុមហ៊ុន GTN Asia Financial Services (Pte.) Ltd." ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** ព្រមទាំងមានការចូលរួមពី **លោកជំទាវអ្នកឧកញ៉ា ម៉ៅ ចំណាន គិតម៉េង** ប្រធាននៃ **ស.ស.ខ.** និង ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ននានា នៅអគារធនាគារ វីង ថៅវើ។



រូបភាព៖ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្ដីពី "កិច្ច-សហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមអភិវឌ្ឍន៍វិស័យមូលបត្រ នៅព្រះរាជាណាចក្រកម្ពុជា"។

## សន្និសីទមូលបត្រប្រចាំឆ្នាំ២០២៥

នាព្រឹកថ្ងៃអង្គារ ១៥កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែតុលា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក ណាង សេរីរ៉ុធ អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ** និងសហការី បានអញ្ជើញចូលរួមសន្និសីទមូលបត្រប្រចាំឆ្នាំ២០២៥ ក្រោមមូលបទ "ការវិវត្តនៃវិស័យមូលបត្រ៖ ចីរភាព, នវានុវត្តន៍, បរិយាបន្ន និងភាពធន់" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ នៅសណ្ឋាគាររ៉េស៊ីដង់សុខា ភ្នំពេញ។



រូបភាព៖ សន្និសីទមូលបត្រប្រចាំឆ្នាំ២០២៥។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែតុលា ឆ្នាំ២០២៥

នាព្រឹកថ្ងៃអង្គារ ១៥កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែតុលា គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែតុលា ឆ្នាំ២០២៥ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកស្រីប្រធាននាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកញ្ញា ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្ដល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែសីហា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកញ្ញា ឆ្នាំ២០២៥។

## វគ្គបណ្ដុះបណ្ដាលស្ដីពី "មូលដ្ឋានគ្រឹះនៃការរៀបចំសូចនាករវាស់វែងសមិទ្ធកម្ម"

ចាប់ពីថ្ងៃពុធ-ព្រហស្បតិ៍ ១-២រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨-៩ ខែតុលា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណៃ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំសហការីចូលរួមជាគណៈអធិបតីក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពី "មូលដ្ឋានគ្រឹះនៃការរៀបចំសូចនាករវាស់វែងសមិទ្ធកម្ម" ក្រោមអធិបតីភាពរបស់

**ឯកឧត្តម គុយ សាវុធ** ទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ វគ្គបណ្ដុះបណ្ដាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹង និងលើកកម្ពស់សមត្ថភាព និងចំណេះដឹងរបស់មន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ដែលទទួលបន្ទុកកិច្ចការតាមដាន និងវាយតម្លៃការរៀបចំសូចនាករវាស់វែងសមិទ្ធកម្មក្នុងវិស័យលើការរៀបចំ និងវាស់វែងប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់ **អ.ស.ហ.** ទាំងកម្រិតផែនការសកម្មភាព និងកម្រិតយុទ្ធសាស្ត្រ និងមានវាគ្មិនជំនាញមកពីវិទ្យាស្ថានសូចនាករសមិទ្ធកម្មគន្លឹះ (The KPI Institute) ដែលមានមូលដ្ឋាននៅប្រទេសម៉ាឡេស៊ី។



**រូបភាព៖** វគ្គបណ្ដុះបណ្ដាលស្ដីពី "មូលដ្ឋានគ្រឹះនៃការរៀបចំសូចនាករវាស់វែងសមិទ្ធកម្ម"។

## កិច្ចប្រជុំស្ដីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.

នាសៀលថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែតុលា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំស្ដីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋានចំណុះនៃ **ន.ប.ធ.** ដោយបានបង្ហាញអំពីសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់ **ន.ប.ធ.** លើបញ្ហាប្រឈម និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្ត្រ ដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅត្រីមាសបន្ទាប់ឱ្យកាន់តែល្អប្រសើរថែមទៀត។



**រូបភាព៖** កិច្ចប្រជុំស្ដីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.។

## កិច្ចប្រជុំស្ដីពី "សេចក្ដីព្រាងផែនការសកម្មភាព និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា"

នាព្រឹកថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែតុលា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំស្ដីពី "សេចក្ដីព្រាងផែនការសកម្មភាព និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ជូ វិជិត្ត រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំនៃក្រសួងពាក់ព័ន្ធ និងអង្គភាពនានាចំណុះ **កសហវ** នៅទីស្ដីការ **កសហវ**។



**រូបភាព៖** កិច្ចប្រជុំស្ដីពី "សេចក្ដីព្រាងផែនការសកម្មភាព និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា"។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សកម្មភាពចុះត្រួតពិនិត្យវឌ្ឍនភាពកិច្ចគាំពារបរិស្ថាន និងសង្គម របស់សមាជិកសហគមកសិកម្មដែលទទួលបានឥណទានពី គម្រោងACSEP-PIU1

នាព្រឹកថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែតុលា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោងACSEP-PIU1, **លោក ប៉ូ សំអាង ប្រធានផ្នែកប្រតិបត្តិការ អមដោយទីប្រឹក្សានិងមន្ត្រីគម្រោង** បានដឹកនាំប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីចុះត្រួតពិនិត្យវឌ្ឍនភាពកិច្ចគាំពារបរិស្ថាន និងសង្គម របស់សមាជិកសហគមកសិកម្មដែលទទួលបានឥណទានពី គម្រោង ACSEP-PIU1 ក្នុងឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ក្នុងគោលបំណង វាយតម្លៃការអនុវត្តកិច្ចគាំពារបរិស្ថាន និងសង្គម ព្រមទាំងស្វែងយល់ពីការអនុវត្តជាក់ស្តែងនៃគម្រោងក្រោមក្របខណ្ឌរបស់ ADB។

បេសកកម្មនេះ មានការចូលរួមពីលោកស្រី លោកស្រី Jocelyn Erlinda Munsayac ប្រធានក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមការងារ តំណាងធនាគារ ADB, អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកគម្រោង ACSEP-PIU2 និងក្រុមការងារ, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1 និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ (ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា)។



**រូបភាព៖** សកម្មភាពចុះត្រួតពិនិត្យវឌ្ឍនភាពកិច្ចគាំពារបរិស្ថាន និងសង្គម របស់សមាជិកសហគមកសិកម្មដែលទទួលបានឥណទានពី គម្រោងACSEP-PIU1។

## កិច្ចប្រជុំពិភាក្សារវាង ន.ប.ធ. និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** និងសហការី បានជួបប្រជុំជាមួយ **ឯកឧត្តមបណ្ឌិត តាំង ខួនលី** **នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី** "តេជោ" អមដោយ **លោកស្រី ហ៊ាន ឡូរីដា នាយកប្រតិបត្តិរងនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"** និងសហការី ដើម្បីពិភាក្សាស្តីពីការចុះបញ្ជីពន្ធដាររបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ក្នុងន័យទទួលបានជាតុចូលបន្ថែមក្នុងការដោះស្រាយភាពជាប់គាំងការចុះបញ្ជីពន្ធដាររបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច។



**រូបភាព៖** មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"។

## កិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ

នាល្ងាចថ្ងៃព្រហស្បតិ៍ ៩រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ កិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០

នារសៀលថ្ងៃសុក្រ ១០រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែតុលា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ អមដោយ **លោក ឃុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងជាប្រធានក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ២០២៦-២០៣០។

## កម្មវិធី Industrial Transformation ASIA-PACIFIC (ITAP) 2025

ចាប់ពីថ្ងៃពុធ-សុក្រ ៨-១០រោចខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ស.ព.២៥៦៩ ត្រូវនឹងថ្ងៃទី១៥-១៧ ខែតុលា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក បៀន យាងជូ ប្រធានការិយាល័យ** និងកញ្ញា **កេត ស្រីនិច អនុប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារ** នៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ បានចូលរួមកម្មវិធី Industrial Transformation ASIA-PACIFIC (ITAP) 2025 ក្រោមប្រធានបទ "Powering the Future with Technology" ក្នុងគោលបំណងដើម្បីស្វែងយល់ពីការលើកកម្ពស់វិស័យឧស្សាហកម្មតាមរយៈបច្ចេកវិទ្យា និងនវានុវត្តន៍។

កម្មវិធីនេះ មានព្រឹត្តិការណ៍សន្និសីទសំខាន់ៗដូចជា របៀបប្រើប្រាស់បញ្ញាសិប្បនិម្មិត ភាពធន់និងនិរន្តរភាពនៃការអនុវត្តការងារជាមួយនឹងការចាប់យកបច្ចេកវិទ្យាថ្មីៗ និងបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ព្រមទាំងមានការតាំងពិព័រណ៍អំពីបច្ចេកវិទ្យាទំនើបសម្រាប់វិស័យឧស្សាហកម្មផងដែរ។




រូបភាព៖ កម្មវិធី Industrial Transformation ASIA-PACIFIC (ITAP) 2025។

## កម្មវិធី "វេទិកាការផ្គូផ្គងគ្រឹះស្ថានហិរញ្ញវត្ថុ ជាមួយកសិធុរកិច្ច សហគមន៍កសិកម្ម និងការដាក់តាំងបង្ហាញផលិតផលកសិកម្ម ក្រោមឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃអង្គារ ១៤ រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែតុលា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែ-

ប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកម្មវិធី "វេទិកាការផ្ដូផ្គងគ្រឹះស្ថានហិរញ្ញវត្ថុ ជាមួយកសិធុរកិច្ច សហគមន៍កសិកម្ម និងការដាក់តាំងបង្ហាញផលិតផលកសិកម្ម ក្រោមឥណទានគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជានាយកគម្រោង**, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **Mr. Anthony Robert Gill ប្រធានផ្នែកប្រតិបត្តិការប្រចាំប្រទេសកម្ពុជា** នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB), **លោក ឡុង ពិសិដ្ឋ មន្ត្រីជាន់ខ្ពស់ធនាគារអភិវឌ្ឍន៍អាស៊ី** ADB និងជាប្រធានគ្រប់គ្រងគម្រោង ACSEP ប្រចាំប្រទេសកម្ពុជា, នៅសណ្ឋាគារ សុខាភ្នំពេញ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងចូលរួមគាំទ្រ និងលើកស្ទួយផលិតផលខ្មែរតាមរយៈការផ្សារភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ និងផ្ដល់ព័ត៌មានផ្សេងៗនៃប្រតិបត្តិការឥណទានគម្រោង ACSEP រវាងគ្រឹះស្ថានហិរញ្ញវត្ថុដែលជាប្រតិបត្តិករឥណទាន ជាមួយកសិធុរកិច្ច, សហគមន៍កសិកម្ម, និងអាជីវករចិញ្ចឹមមាន់ដែលមានសក្ដានុពល ដើម្បីជំរុញនូវការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីឥណទានដែលមានលក្ខណៈអនុគ្រោះពីគម្រោង។ ជាមួយគ្នាកម្មវិធីនេះក៏មានការរៀបចំដាក់តាំងបង្ហាញកសិផលរបស់កសិធុរកិច្ច សហគមន៍កសិកម្ម ដែលទទួលបានកម្ចីពីគម្រោង ACSEP លើផលិតផលកសិកម្មគោលដៅចំនួន ៥ រួមមាន៖ ស្វាយចន្ទី មាន់ស្រែ ដំឡូងមី បន្លែ និងស្វាយ។ បច្ចុប្បន្ន អង្គភាពអនុវត្តគម្រោង (ACSEP-PIU1) បានផ្ដល់ឥណទានដែលសរុបជាទឹកប្រាក់មានចំនួន ១៣.៧ លានដុល្លារអាមេរិក ដល់អតិថិជនចំនួន ៦៦០ រូប។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការជាតិ និងគ្រប់គ្រងបំណុល (GDICDM), តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងអភិវឌ្ឍន៍ជនបទ, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តគោលដៅចាស់ទាំង ៦ និងខេត្តគោលដៅថ្មី, តំណាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC), និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ កម្មវិធី "វេទិកាការផ្ដូផ្គងគ្រឹះស្ថានហិរញ្ញវត្ថុ ជាមួយកសិធុរកិច្ច សហគមន៍កសិកម្ម និងការដាក់តាំងបង្ហាញផលិតផលកសិកម្ម ក្រោមឥណទានគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## កិច្ចប្រជុំលើកទី៣ ប្រចាំឆ្នាំ២០២៥ ស្ដីពី "ធនធានមនុស្ស និងបច្ចេកវិទ្យាការងារ (The 3rd HR & WorkTech Summit Indonesia 2025"

នាថ្ងៃពុធ ១កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែតុលា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក យុត តារាថៃយ អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ** និង**លោក ចេស ចាន់ដេត ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា** បានចូលរួមកិច្ចប្រជុំលើកទី៣ ប្រចាំឆ្នាំ២០២៥ ស្ដីពី "ធនធានមនុស្សនិងបច្ចេកវិទ្យាការងារ (The 3rd HR & WorkTech Summit Indonesia 2025" ក្រោមប្រធានបទ "ការភ្ជាប់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងនវានុវត្តន៍បច្ចេកវិទ្យាសម្រាប់ភាពជោគជ័យនៅកន្លែងធ្វើការ (Harnessing AI and Innovation for Workplace Success" នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងទទួលបានបទពិសោធន៍ ក៏ដូចជាចាប់យកនូវនវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យា WorkTech និងការគ្រប់គ្រងធនធានមនុស្សតាមនវានុវត្តន៍បច្ចេកវិទ្យា សម្រាប់ការងារប្រចាំថ្ងៃរបស់ **ន.ប.ធ.** ក៏ដូចជាការបំពេញនូវមុខងារគ្រប់គ្រង និងត្រួតពិនិត្យតួអង្គ និងភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យបរធនបាលកិច្ចតាមយន្តការបច្ចេកវិទ្យា។

កិច្ចប្រជុំនេះក៏មានការតាំងពិព័រណ៍បង្ហាញផលិតផលបច្ចេកវិទ្យាពីក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្មបច្ចេកវិទ្យាល្បីៗផងដែរ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ កិច្ចប្រជុំលើកទី៣ ប្រចាំឆ្នាំ២០២៥ ស្តីពី "ធនធានមនុស្ស និង បច្ចេកវិទ្យាការងារ (The 3rd HR & WorkTech Summit Indonesia 2025"។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ២កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែតុលា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងរបាយការណ៍តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ ពាក់កណ្តាលអាណត្តិ និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២៥-២០៣០ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## វគ្គបណ្តុះបណ្តាលស្តីពី "ហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម និង ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និង លើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

នាថ្ងៃសុក្រ ៣កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស . ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែតុលា គ.ស.២០២៥ **ន.ប.ធ.** ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ហិរញ្ញប្បទានខ្សែប្រវាក់តម្លៃកសិកម្ម និងការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" ដល់មន្ត្រីបង្គោលនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, ធនាគារស្ថាបនា ភីអិលស៊ី, ធនាគារ វីង, ធនាគារប្រៃសណីយ៍កម្ពុជា, ធនាគារ ហ្វីលីព ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (**ខេមបូឌា**) ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ភីអិលស៊ី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

វគ្គបណ្តុះបណ្តាលនេះ ជាលទ្ធផលនៃការពង្រីកវិសាលភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ ក្នុងកម្រិតទូទាំងប្រទេសបន្ថែមពីលើខេត្តគោលដៅទាំង ៦ ដែលមានស្រាប់ និងត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹង ក៏ដូចជាពង្រឹងសមត្ថភាពដល់មន្ត្រីនៃធនាគារដៃគូទាំងពីរ និងគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារទាំង ៦ ខាងលើ លើការរៀបចំបំពេញព័ត៌មាន ក្នុងទម្រង់ផលប៉ះពាល់ដល់បរិស្ថាននិងសុវត្ថិភាពសង្គម ដែលជាលក្ខខណ្ឌតម្រូវក្នុងការស្នើសុំឥណទាន និងនីតិវិធីប្រតិបត្តិហិរញ្ញប្បទានខ្សែប្រវាក់តម្លៃកសិកម្មក្នុងក្របខណ្ឌគម្រោង ACSEP សមាសភាគទី១ នេះ។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC), គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារទាំង ៦ រួមមាន៖ ធនាគារ វីង, ធនាគារប្រៃសណីយ៍កម្ពុជា, ធនាគារហ្វីលីព ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (**ខេមបូឌា**) ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ភីអិលស៊ី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** វគ្គបណ្តុះបណ្តាលស្តីពី "ហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម និងការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"។

## កម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥"

នាថ្ងៃសុក្រ ១០កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣១ ខែតុលា គ.ស.២០២៥, **ន.ប.ធ.** ដោយមានកិច្ចសហការគាំទ្រពីបណ្តាក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច បានរៀបចំកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ក្រោមប្រធានបទ "បរធនបាលកិច្ចជាថ្នាលធុរកិច្ចប្រកបដោយទំនុកចិត្ត និងអនុលោមភាពច្បាប់" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)** និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** នៅសណ្ឋាគារសុខាភ្នំពេញ ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយបន្ថែមក៏ដូចជាប្រមូលផ្តុំអ្នកជំនាញ និងតួអង្គពាក់ព័ន្ធសំខាន់ៗក្នុងវិស័យបរធនបាលកិច្ច ដើម្បីភ្ជាប់បណ្តាញទំនាក់ទំនង និងទទួលបានទស្សនៈថ្មីៗ ព្រមទាំងផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍អនុវត្តន៍ពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច។

សម្រាប់ការរៀបចំកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" នេះ បានផ្តោតជាសំខាន់ទៅលើការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាអំពីទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនវិស័យបរធនបាលកិច្ច, គុណប្រយោជន៍នៃបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌, ការបន្តស្ថេរភាពហិរញ្ញវត្ថុតជំនាន់, ឱកាសវិនិយោគអចលនទ្រព្យតាមរយៈយន្តការបរធនបាលកិច្ច, ការប្រែក្លាយកម្ពុជាជាទិសដៅថ្មីសម្រាប់ការវិនិយោគតាមរយៈបរធនបាលកិច្ច អចលនទ្រព្យ និងភាពចាំបាច់នៃការប្រើប្រាស់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដោយមានការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយសជាតិ និងអន្តរជាតិ ដែលមានបទពិសោធន៍ច្រើនឆ្នាំ។

ជាពិសេស វេទិកានេះរឹតតែអធិកអធមដោយមានការរៀបចំ៖ ១).ពិធីប្រកាសទទួលស្គាល់សមាគមបរធនបាលកម្ពុជា ជាផ្លូវការ និង២).ពិធីប្រគល់ពានរង្វាន់ឆ្នើមដល់ក្រុមហ៊ុន, ធនាគារ និងបុគ្គលដែលជាប្រតិបត្តិករផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច, ដៃគូសហប្រតិបត្តិការសកម្ម និងអង្គភាពសារព័ត៌មានឆ្នើម ប្រចាំឆ្នាំ២០២៤ ផងដែរ។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក-សមាជិកាក្រុមប្រឹក្សា **អ.ស.ហ.**, ឯកឧត្តម លោកជំទាវ តំណាងក្រសួង/ស្ថាប័ន និងមន្ទីរពាក់ព័ន្ធទាំង ២៥ រាជធានី-ខេត្ត, ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ឧកញ៉ា លោក លោកស្រី វាគ្មិន ភ្ញៀវជាតិ និងអន្តរជាតិ សរុបប្រមាណជាង ៥០០ នាក់។



**រូបភាព៖** កម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥"។

## កម្រងសកម្មភាពក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ក្រោមប្រធានបទ "បរធនបាលកិច្ចជាថ្នាលធុរកិច្ចប្រកបដោយទំនុកចិត្ត និងអនុលោមភាពច្បាប់"

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សូមជូននូវកម្រងរូបភាពនៃវេទិកាពិភាក្សាស្តីពី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ក្រោមប្រធានបទ "បរធនបាលកិច្ចជាថ្នាលធុរកិច្ចប្រកបដោយទំនុកចិត្ត និងអនុលោមភាពច្បាប់" នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ នៅសណ្ឋាគារ សុខា ភ្នំពេញ។




**រូបភាព៖** វេទិកាពិភាក្សាស្តីពី "ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ២០២៥-២០៣៥"។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចបុគ្គល ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក។




**រូបភាព៖** វេទិកាពិភាក្សាស្តីពី "បរធនបាលកិច្ចគ្រួសារ៖ ការបន្តស្ថិរភាពហិរញ្ញវត្ថុតជំនាន់" នៃកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥"។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសញ្ញាបណ្ណបៃតងប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនក្រុមហ៊ុន ហ្វ្រេន កាថេ អ៊ិនវេសមិន ត្រាស (ខេមបូឌា) ម.ក។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចអចលនវត្ថុ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥"។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសញ្ញាបណ្ណបៃតងប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនក្រុមហ៊ុន ហ្វ្រេន កាថេ អ៊ិនវេសមិន ត្រាស (ខេមបូឌា) ម.ក។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចប្រាក់បញ្ញើមានកាលកំណត់ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនក្រុមហ៊ុន ដឹ ហ្វីស ឆាយណា អ៊ិនវេសមេន អេន ត្រាស ឯ.ក។




**រូបភាព៖** ប្រតិបត្តិករបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ទិញ-លក់អចលនវត្ថុ ប្រចាំឆ្នាំ-២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ធនាគារ កាណាឌីយ៉ា ក.អ។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចមូលនិធិភាគហ៊ុនិក ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក។




**រូបភាព៖** ប្រតិបត្តិករបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ទិញ-លក់អចលនវត្ថុ ប្រចាំឆ្នាំ-២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA)។




**រូបភាព៖** ប្រតិបត្តិករបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ទិញ-លក់អចលនវត្ថុ ប្រចាំឆ្នាំ-២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ធនាគារ អេស៊ីលីដា ភីអិលស៊ី។




**រូបភាព៖** ប្រតិបត្តិករបរធនបាលឆ្នើម សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនធនាគារ វីង (ខេមបូឌា) ម.ក។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចសា-ធារណៈ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ បរធនបាលកិច្ចមូលនិធិគន្ធបុប្ផាកម្ពុជា។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ លោក ជា ផល្លារិន បរធនបាលកិច្ចហិរញ្ញវត្ថុអមតៈ។



**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចសា-ធារណៈ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ បរធនបាលកិច្ចមូលនិធិអភិវឌ្ឍន៍ជំនាញ-"ម.អ.ជ."។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" លោក ចាន់ ម៉ាច បរធនបាលកិច្ចហិរញ្ញវត្ថុក្រេឌីត។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចសា-ធារណៈ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ បរធនបាលកិច្ចសហគ្រិនខ្មែរ-"ស.គ.ខ."។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចសា-ធារណៈ ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ លោក ប៊ុន សីហា បរធនបាលកិច្ចហិរញ្ញវត្ថុពាយ័ព្យ ហ្វាយនែនហ្សល ត្រាស់។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើម សម្រាប់បរធនបាលកិច្ចសង្គម ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" ប្រគល់ជូនបរធនបាលកិច្ចអង្គការមូលនិធិអេស៊ីលីដា-ចារឌីន សម្រាប់ការអប់រំ។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើមនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ។




**រូបភាព៖** ក្រុមហ៊ុនបរធនបាលឆ្នើម ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន ស្រ្តងហុល ត្រាសធី ឯ.ក។




**រូបភាព៖** បរធនបាលរូបវន្តបុគ្គលឯករាជ្យឆ្នើមនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ បរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ ។




**រូបភាព៖** ប្រតិបត្តិករបរធនបាលឆ្នើម ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី។




រូបភាព៖ ប្រតិបត្តិករបរធនបាលឆ្នើម ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA)។




រូបភាព៖ ក្រុមហ៊ុនវាយតម្លៃឆ្នើម ក្នុងវិស័យបរធនបាលកិច្ច ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន ស៊ី ភី អែល ខេមបូឌា ប្រភើធី លីមីតធីត។




រូបភាព៖ ប្រតិបត្តិករបរធនបាលឆ្នើម ដែលសកម្មក្នុងការងារសង្គម និងបរិស្ថាន ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ធនាគារ អេស៊ីលីដា ភីអិលស៊ី។




រូបភាព៖ ក្រុមហ៊ុនវាយតម្លៃឆ្នើម ក្នុងវិស័យបរធនបាលកិច្ច ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន អ៊ីនវ៉ា រៀល អ៊ីស្ទេត អ៊ិនវេសមិន អេនវ៉ាលូអេសិន ឯ.ក។




រូបភាព៖ ក្រុមហ៊ុនវាយតម្លៃឆ្នើម ក្នុងវិស័យបរធនបាលកិច្ច ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន មេហ្គា អាសិត មេនេចមេន។




រូបភាព៖ ក្រុមហ៊ុនផ្តល់សេវាសវនកម្មឆ្នើម ក្នុងវិស័យបរធនបាលកិច្ច ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន ប្រាយវ៉េតធើហោវ៉ូខើស៍ (ខេមបូឌា)។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ ក្រុមហ៊ុនផ្តល់សេវាសវនកម្មឆ្នើម ក្នុងវិស័យបរធនបាលកិច្ច ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត ។



រូបភាព៖ ក្រុមហ៊ុនផ្តល់សេវាសវនកម្មឆ្នើម ក្នុងវិស័យបរធនបាលកិច្ច ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ ក្រុមហ៊ុន រ៉ឺចន៍ & ផាតនើរ។



រូបភាព៖ ដៃគូសហប្រតិបត្តិការសកម្ម ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ វិទ្យាស្ថានខេមអេដ ។




រូបភាព៖ ដៃគូសហប្រតិបត្តិការសកម្ម ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា។



រូបភាព៖ អង្គភាពព័ត៌មានឆ្នើម ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ សារព័ត៌មានខេមបូណ្ឌមីស ។



រូបភាព៖ អង្គភាពព័ត៌មានឆ្នើម ប្រចាំឆ្នាំ២០២៤ ដែលបានទទួលពានរង្វាន់នៅក្នុងកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៥" សម្រាប់ សារព័ត៌មាន FRESH NEWS។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888